ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ១៦៥៧ សរ៣

ថ្ងៃសុក្រ ១៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពីការផ្គត់ផ្គង់សម្ភារការិយាល័យ គ្រឿងសង្ហារិម និងសម្ភារបរិក្ខារ សម្រាប់ឆ្នាំ ២០១៩

ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថាក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ នឹងដាក់អោយដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារការិយាល័យ គ្រឿងសង្ហារិម និងសម្ភារបរិក្ខារ សម្រាប់ឆ្នាំ ២០១៩ ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងហាផ្ទៃ ដែលមានអាសយដ្ឋានក្នុងទីស្តីការក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោង ធ្វើការ (ឬទាក់ទងតាមទូរស័ព្ទលេខ ០២៣ ៧២៦ ០៤៥) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង១០:០០ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង១០:០០ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ នៅចំពោះមុខគណៈកម្មការ និងប្រធាន ឬអនុប្រធានក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

បានពិនិត្យត្រឹមត្រូវ

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ព័ត៌មានផ្សេងៗសូមទាក់ទង**
-ទូរស័ព្ទលេខ : ០២៣ ៧២៦ ០៤៥

ចំលងជូន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ" 3